**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....៧៩.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតស្ថានអគ្គកុងស៊ុលកម្ពុជា នៅបរទេស

~~~~~

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមការចាំបាច់ របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា ១** : បង្កើតស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងឆិនតៅ (Qingdao) នៃសាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២** : ស្ថានអគ្គកុងស៊ុលនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មកុងស៊ុលម្នាក់ ដែលមានឋានៈជាអគ្គកុងស៊ុល ។

**មាត្រា ៣** : សមាសភាពមន្ត្រីកុងស៊ុលផ្សេងទៀត នឹងត្រូវកំណត់តាមតំរូវការ នៃការងារជាក់ស្តែង ។

**មាត្រា ៤** : ការចំណាយសំរាប់ប្រាក់បៀវត្សរបស់អគ្គកុងស៊ុល ទីតាំង សេវា សំភារៈប្រើប្រាស់សំរាប់ការិយាល័យ និងរថយន្តបំរើការងារ សំរាប់ស្ថានអគ្គកុងស៊ុល ក្នុងរយៈពេលបីឆ្នាំដំបូង ជាបន្ទុករបស់លោក Zhang Qingping ប្រធានក្រុមហ៊ុន Qingdao Tangnian International Trade and Business Co., Ltd នៅខេត្តសានទុង និង ក្រុមហ៊ុន Billion Fung International Investment and Group Ltd. នៅទីក្រុងហុងកុង ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com
~~~~~